ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តឧត្តរមានជ័យ

លេខ: ០១០ សជណ.ខ្ជ

ឧត្តរមានជ័យ,ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៣

**យោង** : សេចក្តីជូនដំណឹងលេខ ០០៥ សហវ.អពដ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៣ ។

**អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សូមជូនដំណឹងដល់ ឯកឧត្តម-លោកជំទាវ លោក-លោកស្រី** ទាំងអស់មេត្តាជ្រាបថា ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣ ត្រូវចាប់អនុវត្តពីថ្ងៃទី **១៥ ខែ កុម្ភៈ** រហូតដល់ថ្ងៃទី **១៥ ខែ កក្កដា ឆ្នាំ២០១៣** ដោយមិនគិតថាជារបស់រដ្ឋ រឺ ឯកជនឡើយ។ ចំពោះម៉ូតូ ត្រូវទៅបង់ពន្ធនៅ **ធនាគារអេស៊ីលីដា** ទូទាំងខេត្ត។ ឯការត្រួតពិនិត្យលើការបង់ពន្ធនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី **១៦ ខែ កក្កដា ឆ្នាំ ២០១៣** តទៅ ។

ដើម្បីបំពេញកាតព្វកិច្ចបង់ពន្ធនេះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងអស់ ត្រូវបំពេញលិខិតប្រកាសចំនួន ២ សន្លឹក និង ត្រូវប្រគល់បង្កាន់ដៃឆ្នាំ ២០១២ ដល់មន្ត្រីមានសមត្ថកិច្ច សម្រាប់ជាភស្តុតាងបញ្ជាក់ថាមធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះ បានបង់ពន្ធឆ្នាំ ២០១២ រួចហើយ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះណា ដែលមិនមានបង្កាន់ដៃបង់ពន្ធឆ្នាំ ២០១២ ទេ ត្រូវបង់ពន្ធសម្រាប់ឆ្នាំ ២០១២ និង ត្រូវបង់ប្រាក់ពិន័យមួយដងស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតអោយបង់ពន្ធសម្រាប់ឆ្នាំ ២០១៣។ ក្នុងករណីបាត់បង្កាន់ដៃបង់ពន្ធឆ្នាំ ២០១២ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធឆ្នាំ ២០១២ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត នៃទីកន្លែងដែលបានបង់ពន្ធនោះ ។

ក្រោយពេលបង់ពន្ធរួច អ្នកបង់ពន្ធត្រូវទទួលបានបណ្ណបង់ពន្ធ ១ សន្លឹក សម្រាប់បិទជាប់មធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះ និង បង្កាន់ដៃបង់ពន្ធ ១ សន្លឹកទៀត ដែលត្រូវរក្សាទុកជាប់ជាមួយ សម្រាប់បង្ហាញដល់មន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។ ពន្ធនេះត្រូវបានលើកលែងចំពោះ :

១- រថយន្តគិលានសង្គ្រោះ និង រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។

២- មធ្យោបាយដឹកជញ្ជូន និង យានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើអោយការងារការពារប្រទេស សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ។

៣- មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់បេសកកម្មទូត រឺ កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា ។

**អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម -លោកជំទាវ លោក - លោកស្រី** ពិតជាមានការភ្ញាក់រលឹកខ្ពស់ ហើយអញ្ជើញទៅបំពេញកាតព្វកិច្ចបង់ពន្ធនេះ អោយបានរួសរាន់ទាន់ពេលវេលាជាពុំខានឡើយ ។

**អភិបាលខេត្ត**

**ប៊ិច_សុខិន**

<u>ចម្លងជូន</u> :

-ក្រសួងមហាផ្ទៃ

-អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត (ដើម្បីគោរពជូនជ្រាប)

-សាខាពន្ធដារខេត្ត (ដើម្បីអនុវត្ត)

-ស្ថានីយវិទ្យុ និង ទូរទស្សន៍ខ្សែកាប(ដើម្បីផ្សព្វផ្សាយ)

-ឯកសារ-កាលប្បវត្តិ